ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
លេខ.......✓.......................

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យដំណើរការសាកល្បង (Soft Launching)
## "ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា"

ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧នៃរដ្ឋសភា, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដឹកនាំ និងបញ្ចប់ការអភិវឌ្ឍ ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា រួចរាល់ក្នុងការដាក់ឱ្យដំណើរការប្រើប្រាស់។ ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រដ្ឋ ដែលមានតួនាទីជាប្រព័ន្ធកណ្តាលសម្រាប់ផ្លាស់ប្តូរវិក្កយបត្រក្នុងទម្រង់ជាអេឡិចត្រូនិករវាងភាគីអ្នកលក់ ឬអ្នកផ្តល់សេវា និងភាគីអ្នកទិញ ឬអ្នកទទួលសេវា និងមានមុខងារផ្តល់អត្តសញ្ញាណ និងបញ្ជាក់ទទួលស្គាល់វិក្កយបត្រអេឡិចត្រូនិកជាផ្លូវការ ដោយមិនតម្រូវឱ្យបោះពុម្ពវិក្កយបត្រជាក្រដាសឡើយ។ ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា គឺជាឧបករណ៍សម្រាប់ជំរុញការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិកនៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅលើកកម្ពស់តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា, ចូលរួមពង្រឹងអនុលោមភាពបទប្បញ្ញត្តិសារពើពន្ធ, ចូលរួមក្នុងការសម្រេចនូវគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព និងត្រៀមចូលរួមក្នុងកិច្ចសហប្រតិបត្តិការនិងសមាហរណកម្មសេដ្ឋកិច្ចឌីជីថលអាស៊ាន។

ដោយមានការឯកភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,** អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការប្រកាសដាក់ឱ្យដំណើរការសាកល្បង (Soft Launching) នូវ ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា (ប.វ.អ.) ដើម្បីបើកឱ្យដំណើរការចុះឈ្មោះចូលជាសមាជិកប្រើប្រាស់ ប.វ.អ. **ចាប់ពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ នេះតទៅ**។ សេចក្តីដូចបានជម្រាបជូនខាងលើ, អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល សូមអំពាវនាវដល់សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី ព្រមទាំងបណ្តាម្ចាស់ ឬតំណាងក្រុមហ៊ុនអាជីវកម្មទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងរៀបចំចុះឈ្មោះចូលជាសមាជិកនៃ ប.វ.អ. ឬត្រៀមផ្តល់កិច្ចសហការក្នុងការចូលរួមជាបន្តបន្ទាប់ក្នុងការអនុវត្ត។ សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់លេខ +855 81 881 611 ឬ ធ្វើការស្កេន QR Code ខាងក្រោមនេះ។

ថ្ងៃព្រហស្បតិ៍ ១៧កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០២៤

អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល

មជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច, ជាន់ទី៧, វិថី OCIC, សង្កាត់ជ្រោយចង្វារ, ខណ្ឌជ្រោយចង្វារ, រាជធានីភ្នំពេញ
BDC, 7th Floor, OCIC Blvd, Sangkat Chroy Changva, Khan Chroy Changvar, Phnom Penh, CAMBODIA
mef.gov.kh
t.me/mef_gdde
ទូរសព្ទ:(+៨៥៥)១៥ ៨៨១ ៦១១
Phone : (+855) 15 881 611
info@mef.gov.kh
gdde_admin@mef.gov.kh